ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
កិច្ចប្រជុំរួមប្រចាំខែមិថុនា ឆ្នាំ២០២១
របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមិថុនា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយក-នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្តាញវីដេអូ កម្មវិធីZoom សរុបប្រមាណ៤៧នាក់/គណនី។

គោលបំណងនៃកិច្ចប្រជុំដើម្បី :

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និងការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ និងវាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន ព្រមទាំងឧបសគ្គ ក្នុងការអនុវត្តផែនការសកម្មភាព និងផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ប្រចាំខែមិថុនា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម យិនដារ៉ែត។
២- បទបង្ហាញ ស្តីពីកិច្ចប្រជុំកំពូលមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីជំងឺអេដស៍ថ្ងៃទី០៨-១០ ខែមិថុនា ឆ្នាំ២០២១។
៣- មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី
៤- កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម យិនដារ៉ែត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមិថុនា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែកក្កដា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម យិនដារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

I- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន

១- សកម្មភាពការងារដែលសម្រេចបាន ៖

- រៀបចំឯកសារបណ្តុះបណ្តាលសង្គមស៊ីវិល។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយគម្រោង LHSS ពី Data based on SCN#213 តាមបណ្តាញវីដេអូ កម្មវិធី Zoom។
- បានរៀបចំកិច្ចប្រជុំក្រុមការងារ MSM-TG បានចំនួន៣លើក FTCI-SRP បានចំនួន២លើក។
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យដោយឯកឧត្តមវេជ្ជ.**ហោ ប៊ុនឡេង** អនុប្រធាន អ.ជ.ប.ជ.អ។
- ប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ **និង**កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦។
- កិច្ចប្រជុំក្រុម GMC ពិភាក្សាលើប្រធានបទ "យន្តការសុខដុមនីយកម្មលើការងារឆ្លើយតបនឹងមេរោគអេដស៍ប្រកបដោយចីរភាព" ។
- កិច្ចប្រជុំស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ។
- បានរៀបចំអាណត្តិស្នើសុំឥណទានថវិកាតាមកម្មវិធីជំពូក៦១ សម្រាប់ទូទាត់ប្រាក់បេសកកម្មក្នុងប្រទេស ជូនមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចាប់ពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១។
- បានធ្វើផែនការក្របខណ្ឌប្រចាំឆ្នាំ២០២២

២- បញ្ហាប្រឈម ៖

- ស្ថានភាពជំងឺកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងមិនអាចផ្តល់សេវាអប់រំដោយផ្ទាល់បាន។
- ករណីឆ្លងថ្មីនៅតែមានកម្រិតខ្ពស់ ពិសេសក្នុងចំណោមក្រុម MSM និងTG។
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មិនទាន់បានបង្កើត។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ពង្រីកការផ្តល់ឱសថប្រឆាំងមេរោគអេដស៍សម្រាប់រយៈពេលវែង៣-៦ខែ.
- ជំរុញការធ្វើអន្តរគមន៍ការពារជាពិសេសលើប្រជាជនគន្លឹះ (ផ្សព្វផ្សាយអប់រំ ការប្រើស្រោមអនាម័យ PrEP, PEP, U=U)
- ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ ដល់អ្នកផ្ទុកមេរោគអេដស៍តាមរយៈការផ្តល់នៅកន្លែង ART ជាដើម។

II- **បទបង្ហាញ *ស្តីពីកិច្ចប្រជុំកំពូលមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីដំឡើរអេដស៍ថ្ងៃទី០៨-១០ ខែមិថុនា ឆ្នាំ២០២១*** ដោយឯកឧត្តម វេជ្ជបណ្ឌិត **ង៉ា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

- កិច្ចប្រជុំបានលើកឡើងនូវបញ្ហាប្រឈមជាច្រើន ជាពិសេសការរីករាលដាលមេរោគកូវីដ-១៩ ហើយដើម្បីសម្រេចគោលដៅនេះបាន ត្រូវបញ្ចប់វិសមភាព បញ្ចប់ការរាលដាលមេរោគអេដស៍ ត្រូវមានយន្តការដោះស្រាយបំណុល និងគាំទ្រគោលការណ៍របស់ UNAIDS ជារួម ដោយឡែកកម្ពុជា បានសន្យាថានឹងសម្រេចឱ្យបាននូវគោលដៅ ៩៥-៩៥-៩៥ លើកទី១ នៅក្នុងឆ្នាំ២០២៥។
- ត្រូវមានយន្តការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ថ្មី ពិសេសក្រុមបុរសរួមភេទជាមួយបុរសនិងក្រុមបំប្លែងភេទ
- ត្រូវបញ្ចប់វិសមភាព បញ្ចប់ការរាលដាលមេរោគអេដស៍។
- ត្រូវមានយន្តការដោះស្រាយបំណុល។
- ផែនការយុទ្ធសាស្ត្រជាតិលើកទី៥របស់យើង ត្រូវឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្ររបស់ UN។
- ត្រូវអនុវត្តផែនការយុទ្ធសាស្ត្ររបស់ UNAIDS។
- ត្រូវអនុវត្តតាមផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ (២០១៩- ២០២៣)។
- ត្រូវជាក់អ្នកផ្ទុកមេរោគអេដស៍ និងសហគមន៍រងគ្រោះនៅចំកណ្តាល។
- ត្រូវចាត់វិធានការបន្ទាន់ និងផ្លាស់ប្តូរការដឹកនាំ។
- ត្រូវយក ស.ជ.ណ. ២១៣ មកអនុវត្ត។
- ត្រូវពង្រឹងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- ត្រូវជំរុញក្រសួងមហាផ្ទៃឱ្យជួយពន្លឿនដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ក្នុងការរៀបចំសកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍។

២- ករណីក្រុមបុរសរួមភេទជាមួយបុរស និងបំប្លែងភេទ ដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺអេដស៍ ត្រូវគិតគូជួបពិភាក្សាគ្នា និងសិក្សាជាមួយដៃគូគ្រប់លំដាប់ថ្នាក់ ដើម្បីរកវិធីដោះស្រាយ និងទប់ស្កាត់កុំឱ្យរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

៣- អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំណែនាំឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្តធ្វើរបាយការណ៍ ស្តីពីការរៀបចំធ្វើផែនការសកម្មភាព និងផែនការថវិកាប្រយុទ្ធនឹងជំងឺអេដស៍។

៤- ឯកឧត្តម លោកជំទាវដែលទទួលបន្ទុកក្រសួង និងខេត្ត ត្រូវណែនាំដល់ថ្នាក់ក្រសួង និងខេត្តឱ្យបន្តអនុវត្ត ស.ជ.ណ លេខ២១៣ ដើម្បីឆ្លើះទៅទប់ស្កាត់ការចម្លងថ្មី និងរៀបចំផែនការសកម្មភាពអាទិភាពឱ្យស្របគ្នានឹងគោលការណ៍នយោបាយយុទ្ធសាស្ត្រនីមួយៗ ដើម្បីឈានទៅរកភាពជោគជ័យនៃការប្រយុទ្ធនឹងជំងឺអេដស៍។

៥- កិច្ចប្រជុំជាន់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ គឺជាកិច្ចប្រជុំបន្តពីកិច្ចប្រជុំឆ្នាំ២០១៦ ដែលមានគណៈប្រតិភូកម្ពុជាជាច្រើនរូបបានអញ្ជើញទៅចូលរួមហើយរៀបចំរាល់៥ឆ្នាំម្តងរហូតដល់ឆ្នាំ២០៣០

៦- ក្នុងអង្គប្រជុំ មានសេចក្តីថ្លែងការណ៍ជាច្រើនចំណុចណាស់ ចំណុចខ្លះធ្វើឱ្យមានការរសើប ដូចជាសិទ្ធមនុស្ស និងការរើសអើង។

៧- អគ្គលេខាធិការដ្ឋាន ត្រូវបន្តរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រី។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាធ្លុងមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:១២នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃព្រហស្បត្តិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី

អ្នកធ្វើកំណត់ហេតុ

ស៊ឹក_ថាងដាន់